## ១- ឈ្មោះ និង ការចាត់ថ្នាក់នៃប្រភេទឈើ

ឈ្មោះក្នុងស្រុក : បេង

ឈ្មោះវិទ្យាសាស្ត្រ : *Afzelia xylocarpa* Craib

គ្រួសារ : Caesalpinaceae

ចំណាត់ថ្នាក់ជាតិ : ឈើប្រណីត

## ២- ការរាយប៉ាយក្នុងធម្មជាតិ និង ទីកន្លែងដុះដាល

ប្រភេទឈើបេងត្រូវបានរកឃើញដុះនៅក្នុងប្រទេស កម្ពុជា ឡាវ ថៃ វៀតណាម និងភូមា ដើមបេងដុះនៅក្នុងតំបន់ព្រៃត្រូពិចបៃតងជានិច្ច ឬព្រៃល្បោះ។ ប្រភេទនេះដុះនៅលើដីវាលទំនាប ហើយមិនដែលប្រទះឃើញដើមបេងដុះនៅលើភ្នំដែលមានកំពស់លើសពី ៩០០ម ឡើយ។ ជាពិសេសដុះរាយប៉ាយនៅតំបន់ដីរាបស្មើ ឬនៅលើដីជំរាលទាបនៃជ្រោះជ្រលងដងភ្នំខ្សត់ជាតិទឹក។ ដើមបេងអាចដុះលូតលាស់នៅក្នុងតំបន់ដែលមានរយៈកំពស់ពី៥០០-៧០០ម និងក្នុងតំបន់ដែលមានរបបទឹកភ្លៀងធ្លាក់ពី១០០០-១៥០០ម.ម ក្នុងមួយឆ្នាំនៃព្រៃចំរុះប្រភេទ ហើយអាចធន់នឹងរដូវរាំងស្ងួត(រដូវប្រាំង) អូសបន្លាយពេលវែងពី ៥-៦ខែ និងសីតុណ្ហភាពមធ្យមប្រចាំឆ្នាំពី ២០-៣២អង្សាសេ និងសីតុណ្ហភាពអប្បបរមា ១០អង្សាសេ។ នៅប្រទេសកម្ពុជាឈើប្រភេទនេះរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ និងឈានទៅរកការបាត់បង់យ៉ាងឆាប់រហ័សដោយសារការធ្វើអាជីវកម្មហួសកំរិត។ ដើមបេងត្រូវបានចាត់ចូលទៅក្នុងបញ្ជីនៃប្រភេទឈើដែលរងគ្រោះថ្នាក់របស់អង្គការ IUCN (World List of Threatened Trees) ។

## ៣- ការប្រើប្រាស់

សាច់ឈើបេងមានពណ៌លឿងចាស់ ភ្លឺរលោង ប្រកបដោយក្រឡាឆ្នូតៗយ៉ាងល្អ។ សាច់ឈើរឹងមាំ ហើយជាប់ប្រើបានយូរ។ សាច់ឈើគ្រើមៗ មានក្រយៅច្បាស់ពេលដុសខាត់ភ្លឺរលោងល្អ។ នៅប្រទេសកម្ពុជា បេងត្រូវបានចាត់ថ្នាក់ជាឈើប្រណីត និងមានតំលៃដ៏ខ្ពស់ ជាទូទៅត្រូវបានប្រើប្រាស់សំរាប់ធ្វើ តុ ទូ គ្រឿងសង្ហារឹម រូបចំលាក់ផ្សេងៗ ជាឈើសំណង់ ធ្វើក្តារមឈូសសំរាប់អ្នកមាន។ ក្រមួនគ្រាប់បេងអាចយកធ្វើការសំរាប់មូរបារីបានហើយ គ្រាប់បេងពេលនៅខ្ចីកូទីឡេដុង វាមានជាតិខ្លាញ់ អាចបរិភោគបាន។ សំបកយកទៅធ្វើថ្នាំកំលាំង ឬ ថ្នាំបរិភោគបាយបាន និងត្រូវបានប្រើប្រាស់ជាថ្នាំ សំរាប់សម្លាប់ស្បែកសត្វ និងពេទ្យសត្វប្រើព្យាបាលជំងឺឆ្កែ ឆ្មា។

ដើមបេងមានសក្តានុពលល្អសំរាប់ផលិតផលឈើហ៊ុប ប៉ុន្តែការផ្គត់ផ្គង់ឈើបេងនៅមានកំរិត ដូច្នេះគួរមានការស្រាវជ្រាវលើសុរុឡិកម្ម និងរៀបចំប្រភេទនេះបន្ថែមទៀត។ ដោយសារដើមបេងជាប្រភេទឈើផ្តល់ជាតិអាសូតដល់ដី គេអាចដាំតាមបែបកសិ-រុក្ខកម្មដើម្បីកែប្រែគុណភាពដី។ កន្លងមកការដាំត្រូវបានអនុវត្តន៍ក្នុងទ្រង់ទ្រាយតូច ជាពិសេសច្រើនតែដាំសំរាប់គោលបំណងនៃការអភិរក្សពូជឈើប៉ុណ្ណោះ។ ឈើបេងមានសេចក្តីត្រូវការប្រើប្រាស់យ៉ាងខ្ពស់មិនតុល្យភាពនឹងលទ្ធភាពព្រៃ ហើយការធ្វើអាជីវកម្មហួសកំរិត ជាហេតុនាំឱ្យធនធានសេនេទិចត្រូវរងនូវការបំផ្លាញយ៉ាងធ្ងន់ធ្ងរ។

## ៤- លក្ខណៈរុក្ខសាស្ត្រ

- ដើម: ជាដើមឈើមានទំហំធំ មានកំពស់ពី ១០-២០ម ពេលខ្លះអាចមានកំពស់ដល់ ៣០ម និងមានអង្កត់ផ្ចិតដល់ ១,៥ម ហើយពេលខ្លះអាចធំជាង ២មក៏មាន។ ដើមបេងច្រើនតែកោង និងបែកជាចំពាម ហើយជាញឹកញាប់ផ្តល់នូវពកដែលមានគុណភាពដ៏ល្អប្រណីត។
- ស្លឹក: ស្លឹកមានទំហំធំទូលាយ ជាស្លឹកសមាសស្លាបគូ ដែលមានពី ៣-៥គូ និងមានរាងជាពងក្រពើ។ ស្លឹកនីមួយៗមានបណ្តោយ ៥-៩ស.ម និង ទទឹង ៤-៥ស.ម ហើយគ្មានរោមទេ។

## ៥- ការពិពណ៌នាអំពីផ្កា ផ្លែ

- ផ្កា: ផ្កាចេញពីខ្នែងមែកខាងចុងមានរោមព័ទ្ធជុំវិញស្តើង។ ផ្កាតូចមានរាងជាចង្កោម ឬកួរ (Panicles) ដោយមានកេសរឈ្មោលពី ៧-៨ មានបណ្តោយអាចដល់ ៣ស.ម។
- ផ្លែ: ធំក្រាស់ហើយរឹង នៅពេលទុំវាមានពណ៌ត្នោតចាស់ ឬខ្មៅ។ សំបកផ្លែរឹងដូចឈើ (woody pod) ដែលមានបណ្តោយ ១៥-២០ស.ម ទទឹង៧-៩ស.ម។ ផ្លែអាចស្ថិតនៅលើដើមឈើរយៈពេលយូរ មុនពេលសំបកផ្លែរបើក ឬចំហដើម្បីជំរុះគ្រាប់។
- គ្រាប់: គ្រាប់បេងធំហើយរឹង រាងមូលទ្រវែង ពណ៌ខ្មៅភ្លឺរលោង ឬពណ៌ត្នោតចាស់ មានវិជ្ឈមាត្រពី ១,៥-១,៨ស.ម សំបកគ្រាប់ក្រាស់មានក្រមួន គ្រាប់ធំ (aril) ដែលស្ថិតនៅជាប់នឹងពន្លកឬស (radicle) ហើយមានពណ៌លឿងនៅពេលស្ងួត។ ក្នុងមួយគីឡូក្រាមមានពី ១១០-១៦០គ្រាប់។ គ្រាប់បេងដែលបេះពីខេត្តព្រះវិហារក្នុងមួយគីឡូក្រាមមានចំនួន ១០០គ្រាប់ ក្នុងនោះក្រមួនគ្រាប់មានទំងន់ ៤៥%។ គ្រាប់បេងមានសំណើមដំបូងមធ្យម ១០,៩%។



## ៦- រដូវចេញផ្កា ផ្លែ

រដូវចេញផ្ការបស់បេងគឺនៅក្នុងខែមិនា-មេសា ហើយផ្លែទុំនៅខែកញ្ញា-ធ្នូ។ បេងមានផ្កា ផ្លែ ជារៀងរាល់ឆ្នាំ ប៉ុន្តែរយៈពេលផ្តល់ផ្កា ផ្លែច្រើនគឺមានរៀងរាល់ពីរ ឆ្នាំម្តង។

## ៧- ការប្រមូលគ្រាប់ពូជ

ផ្លែបេងទុំនៅពេលដែលសំបកផ្លែប្រែពណ៌ពីបៃតងទៅជាត្នោត ហើយគ្រាប់ឡើងរឹង និងមានពណ៌ត្នោតចាស់។ ផ្លែបេងអាចប្រមូលផ្លែតាមរយៈការឡើងបេះ ឬអង្រួនមែក។ គ្រាប់បេងដែលជ្រុះពីដើម អាចឋិតនៅលើដីរយៈពេលរាប់ខែដោយគ្មានការខូចខាតដល់លទ្ធភាពដុះពន្លក។ បច្ចុប្បន្ន ដើមឈើពេញវ័យត្រូវរងនូវការធ្វើអាជីវកម្មយ៉ាងធ្ងន់ធ្ងរ ដូច្នេះមានការលំបាកខ្លាំងណាស់ ក្នុងការស្វែងរកដើមពេញវ័យសំរាប់ការប្រមូលគ្រាប់។

## ៨- លទ្ធកម្មគ្រាប់ពូជ និង បញ្ហាជំងឺ

បន្ទាប់ពីការប្រមូលផ្លែ ត្រូវបានសំងួតដោយពន្លឺព្រះអាទិត្យ(ហាលថ្ងៃ) នៅលើក្រណាត់កៅស៊ូរហូតទាល់តែសំបកផ្លែទាំងនោះហារ ឬបើកចំហ។ គ្រាប់ទាំងអស់អាចត្រូវបានគេយកចេញដោយការកញ្ជ្រោក ឬដោយវាយបោកផ្លែទាំងនោះនៅក្នុងបាវ។ មានភាពមិនច្បាស់លាស់ថា តើចាំបាច់ត្រូវដកយកចេញនូវក្រមួនគ្រាប់មុនពេលស្តុកទុកដែរឬទេ ដើម្បីចៀសវាងការបំផ្លាញដោយពពួកផ្សិត។ ការយកចេញនូវក្រមួនគ្រាប់នឹងកាត់បន្ថយភាពសំពីងសំពោងប្រហែល